**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សូមក្រាបបង្គំទូលថ្វាយ**
**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ**
**ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**
**ក្នុងពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ យាងចូល ៩០ព្រះវស្សា**

***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!***

ក្នុងឱកាសដ៏នក្ខត្តឫក្ស ពោរពេញដោយក្តីអភិរម្យសោមនស្សរីករាយ ក្នុងពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ យាងចូល ៩០ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥នេះ ទូលព្រះបង្គំជាខ្ញុំ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ សូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្តក្រាបបង្គំទូលថ្វាយនូវព្រះសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរ។

ទូលព្រះបង្គំជាកូន ចៅ ចៅទួតទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតសម្តែងថ្វាយនូវកតញ្ញុតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតចំពោះព្រះមហាករុណាធិគុណដ៏ធំធេងរបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលមានចំពោះជាតិ និងប្រជារាស្ត្រតាមរយៈព្រះរាជសកម្មភាពមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរបស់ស្ត្រី ព្រមទាំងវិស័យសង្គមកិច្ចជាដើម។ ជាពិសេស ព្រះអង្គ ទ្រង់តែងតែមានទឹកព្រះទ័យជ្រះថ្លាបរិសុទ្ធ និងសព្វព្រះរាជហឫទ័យប្រោសព្រះរាជទាននូវព្រះរាជទ្រព្យយ៉ាងច្រើនជួយដល់ប្រជានុរាស្ត្រទូទៅនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តលើកហត្ថប្រណម្យបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ទេវតាឆ្នាំថ្មី ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងបារមីនៃអតីតព្រះមហាក្សត្រ មហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ សូមទ្រង់ប្រោះព្រំសព្ទសាធុការពរជ័យសិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈ សូមព្រះអង្គប្រកបដោយ ព្រះរាជសុខភាពល្អបរិបូរ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់នៅជាម្លប់ដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នាជាកូន ចៅ ចៅទួតរបស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃពុធ ៩ កើត ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៥
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**